**រាជធានីភ្នំពេញ ប្រទេសកម្ពុជា៖**
**សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC)**
គា គន្ធា
ទូរស័ព្ទ៖ (855) 23 863 200
អ៊ីមែល៖ kkea@ifc.org

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា៖**
**ធនាគារជាតិនៃកម្ពុជា**
អែម កំណាន់
ទូរស័ព្ទ៖ (855) 17 934 935
អ៊ីមែល៖ emkamnan@nbc.org.kh

# សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ សហការជាដៃគូជាមួយធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងអភិបាលកិច្ច

**រាជធានីភ្នំពេញ ប្រទេសកម្ពុជា ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១៦** - សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសមាជិកមួយរបស់ធនាគារពិភពលោក បានចុះហត្ថលេខាលើអនុស្សារណៈនៃការយល់គ្នាមួយ ជាមួយនឹងធនាគារជាតិនៃកម្ពុជា ដើម្បីពង្រឹងអភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ កិច្ចសហប្រតិបត្តិការនេះមានគោលបំណងបង្កើនតម្លាភាព និងទំនុកចិត្តរបស់សាធារណជនមកលើវិស័យធនាគារ ។

IFC នឹងជួយធនាគារជាតិនៃកម្ពុជាបង្កើនសមត្ថភាពនិយ័តកម្ម ការត្រួតពិនិត្យ និងពង្រឹងការអនុវត្តច្បាប់ តាមរយៈការរៀបចំនិងផ្តល់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលាស្តីពីអភិបាលកិច្ច ដល់មន្ត្រីធនាគារជាតិនៃកម្ពុជា ។ ធនាគារជាតិនៃកម្ពុជាដោយមានកិច្ចសហការជាមួយ IFC នឹងរៀបចំក្រមអភិបាលកិច្ចដែលចែងអំពីការអនុវត្តល្អនៃអភិបាលកិច្ចសម្រាប់ដាក់ចេញឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជាគោរពតាម ។

លោក រ័ត្ន សុវណ្ណនរៈ អគ្គនាយករងត្រួតពិនិត្យ នៃធនាគារជាតិនៃកម្ពុជា បានលើកឡើងថា "ការគ្រប់គ្រងហានិភ័យប្រុងប្រយ័ត្ន និងការត្រួតពិនិត្យផ្ទៃក្នុង គឺជាកត្តាសំខាន់សម្រាប់ការអភិវឌ្ឍវិស័យធនាគាររបស់ប្រទេសកម្ពុជាប្រកបដោយនិរន្តរភាព ។ យើងរំពឹងថាគម្រោងនេះនឹងជំរុញឲ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ក្នុងការបន្តលើកកម្ពស់ការអនុវត្តអភិបាលកិច្ចនៃគ្រឹះស្ថានរបស់ខ្លួន ដើម្បីឈានទៅរកការធ្វើសមាហរណកម្មទៅក្នុងប្រព័ន្ធហិរញ្ញវត្ថុសកល" ។

មុនពេលមានកិច្ចសហការជាមួយ IFC ធនាគារជាតិនៃកម្ពុជាក៏បានផ្តោតការយកចិត្តទុកដាក់លើការពង្រឹងអភិបាលកិច្ច តាមរយៈការចេញនូវបទប្បញ្ញត្តិផ្សេងៗសម្រាប់គ្រប់គ្រង និងត្រួតពិនិត្យ

អភិបាលកិច្ចរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ។ បន្ថែមពីលើការខិតខំប្រឹងប្រែងរបស់ធនាគារជាតិនៃកម្ពុជា ការផ្តល់ជំនួយពី IFC នឹងរួមចំណែកយ៉ាងសំខាន់ដល់ការពង្រីកវិសាលភាពនៃការកសាងសមត្ថភាពដើម្បីលើកស្ទួយប្រសិទ្ធភាពនៃការអនុវត្ត និងការគោរពតាមអភិបាលកិច្ចល្អនៅក្នុងវិស័យធនាគារ ។

ស្ថាប័នទាំងពីរនឹងសហការគ្នារៀបចំសិក្ខាសាលាជាសាធារណៈជាបន្តបន្ទាប់ដើម្បីបង្កើនការយល់ដឹងអំពីគោលការណ៍អភិបាលកិច្ច ។ សកម្មភាពទាំងនេះជាមធ្យោបាយដែលអាចបន្តពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ការអនុវត្តតាមច្បាប់ និងមុខងារត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាព ក្នុងវិស័យធនាគារ។

Kyle Kelhofer នាយក IFC ប្រចាំប្រទេសកម្ពុជា ឡាវ និងវៀតណាម បានលើកឡើងថា "កិច្ចសហប្រតិបត្តិការរបស់យើងជាមួយធនាគារជាតិនៃកម្ពុជា នឹងជួយបង្កើនតម្លាភាព និងការគ្រប់គ្រងហានិភ័យក្នុងវិស័យធនាគារ កាន់តែមានភាពល្អប្រសើរជាងមុន។ ការណ៍នេះនឹងជួយឲ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុកាត់បន្ថយហានិភ័យនៃការផ្តល់កម្ចី និងបង្កើនលទ្ធភាពទទួលបានឥណទានសម្រាប់ក្រុមហ៊ុនដែលប្រកបអាជីវកម្មនៅកម្ពុជា ដែលកត្តាទាំងនេះនឹងរួមចំណែកដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយចីរភាព ។"

IFC បានចូលរួមក្នុងការអនុមតិ ក្រម ច្បាប់ និងបទប្បញ្ញត្តិស្តីពីអភិបាលកិច្ចចំនួន ៩៥ ក្នុងប្រទេស ជាង ៣០ ទូទាំងពិភពលោក។ នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច IFC បានរៀបចំសៀវភៅណែនាំស្តីពីអភិបាលកិច្ចទីមួយ សម្រាប់បណ្តាក្រុមហ៊ុននៅប្រទេសវៀតណាម និងបានជួយដល់អាជ្ញាធរសេវាកម្មហិរញ្ញវត្ថុឥណ្ឌូនេស៊ី ដែលមានឈ្មោះថា Otoritas Jasa Keuangan ឬហៅកាត់ថា OJK ដើម្បីរៀបចំផែនទីបង្ហាញផ្លូវ និងក្រមអភិបាលកិច្ច។

កម្មវិធីអភិបាលកិច្ចរបស់ IFC នៅតំបន់អាស៊ីបូព៌ា និងប៉ាស៊ីហ្វិច ទទួលបានជំនួយឧបត្ថម្ភពីរដ្ឋលេខាធិការដ្ឋានកិច្ចការសេដ្ឋកិច្ចនៃប្រទេសស្វីស។

## អំពីសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ

សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ (IFC) ដែលជាសមាជិកមួយនៃធនាគារពិភពលោក គឺជាស្ថាប័នអភិវឌ្ឍន៍ធំជាងគេ ដែលធ្វើការផ្តោតសំខាន់ទៅលើវិស័យឯកជន នៅបណ្តាប្រទេសកំពុងរីកចម្រើន។ យើងប្រើប្រាស់មូលធន ជំនាញ និងឥទ្ធិពលរបស់យើង ធ្វើការជាមួយសហគ្រាសអាជីវកម្មជាង២០០០ ដើម្បីបង្កើតឱកាស នៅទីកន្លែងដែលត្រូវការបំផុត ។ ក្នុងឆ្នាំសារពើពន្ធ ២០១៥ ការវិនិយោគរយៈពេលវែងរបស់យើងនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ បានកើនឡើងដល់ជិត ១៨ ប៊ីលានដុល្លារអាមេរិក ។

ការវិនិយោគនេះបានជួយវិស័យឯកជនឲ្យដើរតួនាទីយ៉ាងសំខាន់ក្នុងកិច្ចប្រឹងប្រែងសកល ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងលើកតម្កើងវិបុលភាព ។ សំរាប់ព័ត៌មានបន្ថែម សូមមើល www.ifc.org ។

## សូមភ្ជាប់ទំនាក់ទំនងជាមួយយើង

www.ifc.org/eastasia
www.twitter.com/IFC_EAP
www.facebook.com/IFCwbg
www.youtube.com/IFCvideocasts
www.ifc.org/SocialMediaIndex

## អំពីធនាគារជាតិនៃកម្ពុជា

ធនាគារជាតិនៃកម្ពុជា ដែលជាធនាគារកណ្តាលរបស់ប្រទេសកម្ពុជា គឺជាអាជ្ញាធររូបិយវត្ថុ និងត្រួតពិនិត្យប្រព័ន្ធធនាគារ នៅកម្ពុជា។ បេសកកម្មចម្បងរបស់ធនាគារជាតិនៃកម្ពុជា គឺកំណត់ និងដឹកនាំគោលនយោបាយរូបិយវត្ថុ ក្នុងគោលដៅរក្សានូវស្ថិរភាពថ្លៃ សំដៅរួមចំណែកជំរុញការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងនាមជាអាជ្ញាធរត្រួតពិនិត្យ ធនាគារជាតិនៃកម្ពុជាជាអ្នកផ្តល់និងដកហូតអាជ្ញាប័ណ្ណ ចេញបទប្បញ្ញត្តិ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ នៅកម្ពុជា។ ធនាគារជាតិនៃកម្ពុជាធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច និងរូបិយវត្ថុជាប្រចាំ ចេញផ្សាយរបាយការណ៍ និងព្រឹត្តបត្រផ្សេងៗ ត្រួតពិនិត្យប្រព័ន្ធទូទាត់ជាតិ ដំឡើងតារាងស្ថិតិជញ្ជីងទូទាត់ និងចូលរួមក្នុងការគ្រប់គ្រងបំណុល និងឥណទេយ្យក្រៅប្រទេស ។ សំរាប់ព័ត៌មានបន្ថែម សូមមើល www.nbc.org.kh ។

## សូមភ្ជាប់ទំនាក់ទំនងជាមួយយើង

www.facebook.com/nationalbankofcambodiaofficial
www.twitter.com/nbccambodia